# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៩

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានដំណើរការយ៉ាងប្រសិទ្ធភាពក្នុងការបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សីចំនួនបីរូប ហើយនិងបានចាប់ផ្តើមតាំងសំណួរដេញដោលទៅលើសាក្សីទីបួនផងដែរ ទោះបីជាជួបប្រទះនឹងបញ្ហានីតិវិធីមួយចំនួនដែលបានគំរាមប៉ះពាល់ដល់ការបន្តកិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២ វគ្គទី២ នេះក៏ដោយ។ ការិយាល័យសហព្រះរាជអាជ្ញា បានផ្សព្វផ្សាយនាពេលថ្មីៗនេះថា បានចាប់ផ្តើមដាក់បញ្ចូលនូវសេចក្តីថ្លែងការណ៍សម្ងាត់មួយចំនួនពីការស៊ើបអង្កេតលើសំណុំរឿង០០៤ ទៅក្នុងសំណុំឯកសារនៃសំណុំរឿង០០២ វគ្គទី២នេះ ដោយសារតែសេចក្តីថ្លែងការណ៍ទាំងនេះ មានបញ្ចូលនូវព័ត៌មានដាក់បន្ទុក និងដោះបន្ទុក ដែលមានពាក់ព័ន្ធនឹងការជំនុំជម្រះលើសំណុំរឿងបច្ចុប្បន្ន។ ក្រុមការពារក្តីទាំងពីរ ជាមួយនឹងការគាំទ្រដោយតុណ្ហីភាព (យល់ព្រមដោយស្ងៀមស្ងាត់) ពីសំណាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឲ្យមានការពន្យារពេលលើការបន្តការជំនុំជម្រះនេះ ដើម្បីមានពេលវេលាក្នុងការត្រួតពិនិត្យលើសេចក្តីថ្លែងការណ៍ថ្មីៗទាំងនេះ ដោយសារតែប្រហែលមានភស្តុតាងថ្មីមួយចំនួនអាចមានផលប៉ះពាល់ដល់ការផ្តល់សក្ខីកម្មរបស់សាក្សី ក្នុងផ្នែកនៃការជំនុំជម្រះបច្ចុប្បន្ន ស្តីពីស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូង បានដំណើរការទៅមុខដោយស្តាប់សក្ខីកម្មរបស់សាក្សីចំនួនបួនរូបក្នុងសប្តាហ៍នេះ បន្ទាប់ពីបានធ្វើការកំណត់លើការដាក់បញ្ចូលនូវសេចក្តីថ្លែងការណ៍ថ្មីៗទាំងនេះ ថាមិនមានពាក់ព័ន្ធនឹងទៅនឹងការតាំងសំណួរដេញដោលទៅលើសាក្សីទាំងនេះឡើយ ហើយអង្គជំនុំជម្រះក៏បានប្រកាសផងដែរពីការផ្លាស់ប្តូរមួយចំនួនលើកាលវិភាគសវនាការសម្រាប់ពីរសប្តាហ៍បន្ទាប់ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ភាគីទាំងអស់ក្នុងការ

ត្រួតពិនិត្យលើសេចក្តីថ្លែងការណ៍ថ្មីៗនៃសំណុំរឿង០០៤ នេះ។ ទោះបីជាមានការព្រួយបារម្ភចំពោះការពន្យារពេលនៃសវនាការបានលើកឡើង អង្គជំនុំជម្រះបានទទួលជោគជ័យក្នុងការបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សីជាព្រះសង្ឃ ដែលត្រូវបានគេចាប់ផ្សឹក និងបង្ខំឲ្យធ្វើពលកម្មនៅក្រោមរបបខ្មែរក្រហម ហើយនិងសក្ខីកម្មរបស់ប្រជាជន "មូលដ្ឋាន" ពីរនាក់ ដែលបានរៀបរាប់ពីការរស់នៅក្នុងសហករណ៍ត្រាំកក់របស់ពួកគេ។ ក្នុងវគ្គសវនាការដ៏ខ្លីកាលពីថ្ងៃព្រហស្បតិ៍ ទី១៩ ខែកុម្ភៈ អង្គជំនុំជម្រះបានចាប់ផ្តើមស្តាប់សក្ខីកម្មរបស់អតីតឆ្មាំគុកនៅក្រាំងតាចាន់ ដែលកាលណោះត្រូវបានគេស្គាល់ថាជា "ឌុចតូច"។ របាយការណ៍នេះ ត្រួតពិនិត្យលើសក្ខីកម្មចំនួនបួន វិភាគលើការដាក់បញ្ចូលសេចក្តីថ្លែងការណ៍នៃសំណុំរឿង០០៤ ធ្វើជាភស្តុតាង និងពិភាក្សាលើបញ្ហាដទៃទៀតនៃនីតិវិធី និងការគ្រប់គ្រងសវនាការ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ចូហាន់ណា ហាម៉ាក គីនប៉ហ្គ (Johanna Hamark Kindborg), ឡូញ ង៉ែត, ដាញ៉ែល ម៉ាតថេស៍ (Daniel Mattes), ក្លែរ អ៊ឹម.ស៊ី ម៉ូឡិន (Claire McMullen), តាយ លីណា, ហ្វីប៊ី សាប៊ីន (Phoebe Sabin), ឡូស៊ី ស៊ូលីវ៉ាន់(Lucy Sullivan), ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និង ការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានា ក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។